# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦៧ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃ សៅរ៍ ២ រោច ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃ ចន្ទ ១២រោច ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃ ចន្ទ ៤ កើត ខែ បុស្ស ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០២២ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ជូនរដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ និងក្រសួងអប់រំ យុវជន និងកីឡា ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម÷

ឯកតា÷ ពាន់រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ ២០២៣ | ឥណទានមុនផ្ទេរ | ការផ្ទេរ | | ឥណទានថ្មីក្រោយផ្ទេរ |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | ការផ្ទេរចេញ | | | | 52.881.000 | |
| | ជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) | | | | 52.881.000 | |
| 69 | ចំណាយមិនបានគ្រោងទុក | 1.713.847.000 | 1.713.847.000 | - | 52.881.000 | 1.660.966.000 |
| | ការផ្ទេរចូល | | | 52.881.000 | | |
| | ០២-រដ្ឋសភា | | | 8.942.000 | | |
| 61 | សេវាកម្ម | 37.790.000 | 37.790.000 | 8.942.000 | - | 46.732.000 |
| | ០៤-ក្រុមប្រឹក្សាធម្មនុញ្ញ | | | 1.200.000 | | |
| 60 | ការទិញ | 1.683.000 | 1.683.000 | 1.200.000 | - | 2.883.000 |
| | ០៥.១-ទីស្តីការគណៈរដ្ឋមន្ត្រី | | | 1.000.000 | | |
| 65 | ឧបត្ថម្ភធន | 178.397.000 | 178.397.000 | 1.000.000 | - | 179.397.000 |
| | ១៤-ក្រសួងផែនការ | | | 31.739.000 | | |
| 60 | ការទិញ | 4.338.600 | 4.338.600 | 7.447.000 | - | 11.785.600 |
| 61 | សេវាកម្ម | 10.450.400 | 10.450.400 | 24.292.000 | - | 34.742.400 |
| | ១៦-ក្រសួងអប់រំ យុវជន និងកីឡា | | | 10.000.000 | | |
| 62 | អត្ថប្រយោជន៍សង្គម | 96.005.100 | 96.005.100 | 10.000.000 | - | 106.005.100 |

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់÷

១)- ផ្តល់ជូនរដ្ឋសភា សម្រាប់ទូទាត់ចំណាយជួសជុលអគាររដ្ឋសភាចំនួន ៥អគារ ក្នុងនោះ÷ អគារ D (អគាររដ្ឋបាល), អគារ D1, B, C (អគារតំណាងរាស្ត្រ) និងអគារ A (សាលប្រជុំធំនិងការិយាល័យធ្វើការសម្តេចប្រធាន) ចំនួន ១ ៤៤២ លានរៀល និងសម្រាប់ទូទាត់ចំណាយរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី ៤៣ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះក្នុងឆ្នាំ ២០២២ ចំនួន ៧ ៥០០ លានរៀល។

២)- ផ្តល់ជូនក្រុមប្រឹក្សាធម្មនុញ្ញចំនួន ១ ២០០ លានរៀល សម្រាប់ទិញរថយន្តថ្មីចំនួន ៣ គ្រឿង ជូនសមាជិកថ្មីនៃក្រុមប្រឹក្សាធម្មនុញ្ញចំនួន ៣ រូប ដែលទើបចូលកាន់តំណែង។

៣)-ផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រីចំនួន ១ ០០០ លានរៀល ដើម្បីផ្តល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សម្រាប់សាងសង់ទីទួលសុវត្ថិភាព។

៤)-ផ្តល់ជូនក្រសួងផែនការចំនួន ៣១ ៧៣៩ លានរៀល សម្រាប់អនុវត្តការងារជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ ២០២៣។

៥)-ផ្តល់ជូនក្រសួងអប់រំ យុវជន និងកីឡាចំនួន ១០ ០០០ លានរៀល ដើម្បីផ្តល់ជូនសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) រៀបចំខួប ១០ ឆ្នាំ នៃព្រឹត្តិការណ៍អង្គរសង្ក្រាន្ត។

**មាត្រា៣ .-**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១១រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ